ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង** **សាធារណៈ / Public**

ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១២

**ជូនចំពោះ:** **មេធាវីការពារជនជាប់ចោទ អៀង សារី**

**ពី:** Susan LAMB **មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន:** **ប្រធានអង្គជំនុំជម្រះសាលាដំបូង,លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង និងភាគីនៃសំណុំរឿង ០០២**

**កម្មវត្ថុ:** **ចម្លើយតបទៅនឹងលិខិតរបស់លោកចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១២ ពាក់ព័ន្ធនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់ជនជាប់ចោទ អៀង សារី ដោយអនុលោមតាមវិធាន ៨៧(៤) (ឯកសារ** E172/24/4/1)

១. យោងលិខិតខាងលើដែលចោទថាសេចក្ដីសម្រេច E172/24/4 របស់អង្គជំនុំជម្រះសាលាដំបូង មានកំហុសក្នុងការសម្រេចថាឯកសារថ្មីៗក្នុងប្រភេទឯកសារ (ក) ដល់ (គ) ដូចដែលបានរៀបរាប់នៅក្នុងសេចក្ដីសម្រេចនោះ ពុំមានអត្ថិភាពនៅចំពោះមុខអង្គជំនុំជម្រះឬភាគីឡើយ។ មេធាវីរបស់ជនជាប់ចោទ អៀង សារី ក៏បានចោទប្រកាន់ទៀតថាសេចក្ដីសម្រេចនេះពុំមានសំអាងហេតុគ្រប់គ្រាន់ និងបានអនុវត្តបទដ្ឋានផ្សេងមួយទាក់ទិននឹងឯកសារទាំងនេះ ខុសពីឯកសារស្រដៀងនេះ ដែលការិយាល័យសហព្រះរាជអាជ្ញាបានដាក់ដោយអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 17 / 07 / 2012
ម៉ោង (Time/Heure) : 11:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: UCH ARUN

២. នីតិវិធីសមស្របសម្រាប់ការជំទាស់នឹងសេចក្តីសម្រេចតាមផ្លូវតុលាការ គឺពុំមែនតាមរយៈលិខិតមួយដែលបានផ្ញើមកមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះនោះទេ ប៉ុន្តែជាបណ្តឹងសារទុក្ខទៅលើសេចក្តីសម្រេចនោះ តាមពេលវេលាសមស្រប។ ហេតុដូច្នេះ ចម្លើយតបនេះពុំឆ្លើយតបទៅលើខ្លឹមសារនៃការចោទប្រកាន់អំពីវិការៈនៅក្នុងសំអាងហេតុរបស់អង្គជំនុំជម្រះ ឬកំហុសផ្សេងៗដែលត្រូវបានចោទប្រកាន់ឡើយ។ ដើម្បីផលប្រយោជន៍នៃការប្រព្រឹត្តទៅនៃកិច្ចដំណើរការនីតិវិធីប្រកបដោយប្រសិទ្ធភាព នាងខ្ញុំបានចោទជាសំណួរថាតើសេចក្តីសម្រេច E172/24/4 អាចបានផ្អែកលើមូលដ្ឋានអង្គហេតុពុំត្រឹមត្រូវ និងថាតើវិធានការកែតម្រូវមានភាពចាំបាច់ដើម្បីផលប្រយោជន៍នៃយុត្តិធម៌ដែរ ឬយ៉ាងណា។

៣. ទាក់ទិននឹងឯកសារថ្មីៗក្នុងប្រភេទឯកសារ (ក) ដល់ (គ) មេធាវីការពារជនជាប់ចោទ អៀង សារី បានបញ្ជាក់ថាខ្លួន "បានស្នើសុំឱ្យដាក់លេខ ERN លើឯកសារទាំងនេះ និងដាក់បញ្ចូលឯកសារទាំងនេះទៅក្នុងប្រព័ន្ធផ្ទុកឯកសាររួម" (ឯកសារ E172/24/3, កថាខណ្ឌ ៥ (មានបន្ថែមការសង្កត់ន័យ)។ ថ្វីបើអង្គជំនុំជម្រះនឹងមានចំណាត់ការសមស្របដើម្បីផ្ទៀងផ្ទាត់ព័ត៌មានដែលត្រូវបានផ្តល់មកខ្លួនក៏ដោយ ក៏អង្គជំនុំជម្រះរមែងផ្អែកជាចាំបាច់លើសេចក្តីបញ្ជាក់របស់ភាគីនៅក្នុងឯកសារដែលភាគីបានដាក់។ បើទោះជាបែបនេះក្តី អង្គជំនុំជម្រះទទួលស្គាល់ថាឯកសារក្នុងប្រភេទ (ក) ដល់ (គ) ដូចដែលមេធាវីការពារជនជាប់ចោទបានរៀបរាប់នៅក្នុងសំណើ E172/24/3 អាចឱ្យភាគីពិនិត្យមើលបាននៅក្នុងប្រព័ន្ធផ្ទុកឯកសាររួម ផ្ទុយទៅនឹងអ្វីដែលត្រូវបានលើកឡើងនៅក្នុងកថាខណ្ឌ ៦ នៃសេចក្តីសម្រេច E172/24/4។

៤. ប៉ុន្តែដូចដែលសេចក្តីសម្រេច E172/24/4 ចែងច្បាស់ថា អត្ថិភាព ឬនត្ថិភាពនៃឯកសារនេះនៅក្នុងប្រព័ន្ធផ្ទុកឯកសាររួម ពុំមែនជាមូលដ្ឋាននៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះឡើយ។ ថ្វីបើការដាក់ភស្តុតាងថ្មីដែលភាគីបានស្នើសុំនៅក្នុងប្រព័ន្ធផ្ទុកឯកសាររួម អាចជាវិធានការដ៏មានសារៈប្រយោជន៍មួយនៅក្នុងការធ្វើឱ្យភាគី និងអង្គជំនុំជម្រះ អាចពិនិត្យមើលបានក៏ដោយ ក៏វាពុំមែនមានតម្លៃស្មើទៅនឹងការទទួលយកភស្តុតាងថ្មី ដោយអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងនោះទេ។ ឯកសារនេះអាចត្រូវបានទទួលយក លុះត្រាណាអង្គជំនុំជម្រះសាលាដំបូងពិចារណាតាមឆន្ទានុសិទ្ធិរបស់ខ្លួន លើលក្ខខណ្ឌតម្រូវដែលមាននៅក្នុងអនុវិធាននោះថាបានបំពេញរួចហើយប៉ុណ្ណោះ។ ដូចសំអាងហេតុដែលបានផ្តល់ពាក់ព័ន្ធនឹងឯកសារដែល

សហព្រះរាជអាជ្ញាបានស្នើសុំក្នុងសំណើ E172/24/4 អង្គជំនុំជម្រះបានទទួលយកមួយផ្នែកនៃសំណើរបស់មេធាវីការពារជនជាប់ចោទ អៀង សារី ស្នើសុំទទួលយកឯកសារថ្មីដែលត្រូវបានស្នើឡើង ថ្វីបើឯកសារទាំងនេះមានរួចរាល់ហើយកាលពីពេលមុននេះ (ឧទាហរណ៍ នៅពេលដែលឯកសារដែលត្រូវបានស្នើសុំពាក់ព័ន្ធជិតស្និទ្ធទៅនឹងភស្តុតាងផ្សេងៗ ដែលស្ថិតនៅចំពោះមុខអង្គជំនុំជម្រះរួចរាល់ហើយ) និងបានទទួលយកសំណើសុំលើកទីពីររបស់ជនជាប់ចោទ អៀង សារី អនុលោមតាមវិធាន ៨៧(៤) ពាក់ព័ន្ធនឹងឯកសារដែលត្រូវបានប្រើប្រាស់ក្នុងអំឡុងនៃការសាកសួរដេញដោលអ្នកជំនាញ David Chandler (ឯកសារ E172/24/5) ផ្អែកលើមូលដ្ឋានដដែលនេះ។

៥. គួរបញ្ជាក់ថាថ្វីបើអង្គជំនុំជម្រះពុំបានពិចារណាទៅលើឯកសារសេសសល់ ដែលឯកសារ E172/24/4 លើកយកមកសំអាង ដើម្បីបំពេញលក្ខខណ្ឌតម្រូវនៃវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងក៏ដោយ ក៏សេចក្តីសម្រេចនេះគួសបញ្ជាក់យ៉ាងច្បាស់ថា មេធាវីការពារជនជាប់ចោទ អៀង សារី ពុំមានឧបសគ្គអ្វីឡើយក្នុងការស្នើសុំខ្លឹមសារនៃឯកសារទាំងនេះនៅពេលរៀបចំសំណួរសម្រាប់សួរអ្នកជំនាញ ដរាបណាមេធាវីការពារជនជាប់ចោទ អៀង សារី ផ្តល់ការជូនដំណឹងក្រៅផ្លូវការជាមុនអំពីឯកសារនេះទៅអង្គជំនុំជម្រះ និងភាគីផ្សេងៗ។ ដោយហេតុថាចាប់តាំងពីពេលនោះមក មេធាវីការពារជនជាប់ចោទ អៀង សារី បានផ្តល់លេខ ERNs សម្រាប់ឯកសារស្ថិតក្នុងប្រភេទ (ក) ដល់ (គ) នៅក្នុងប្រព័ន្ធផ្ទុកឯកសាររួម លក្ខខណ្ឌខាងក្រោយនេះត្រូវបានបំពេញរួចរាល់។